# សេចក្ដីសង្គ្រោះ និងការលើកដំកើង

អែលឌើរ័សុល អិម ណិលសុន
នៃក្រុមសាវក 12 នាក់

ដោយសេចក្ដីរីករាយ យើងសូមស្វាគមន៍អែលឌើរ ឌី ថត គ្រីស្ដូហ្វឺសិន មកកាន់ក្រុមសាវក 12 នាក់ ។ យើងសូមគាំទ្រគណៈប្រធានទីមួយដ៏អស្ចារ្យនេះ និងអស់អ្នកដែលត្រូវបានហៅ ដោយអស់ពីដួងចិត្តរបស់យើង ។

បងប្អូនប្រុសស្រីទាំងឡាយ នៅពេលយើងបានទទួលដំណឹងថា ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី បានទទួលមរណភាពរំពេចនោះ យើងម្នាក់ៗទទួលអារម្មណ៍នៃការបាត់បង់ដ៏ជ្រាលជ្រៅ ។ ប៉ុន្តែ ដោយដឹងថា វាសនារបស់លោកស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ នោះយើងជឿជាក់ថាអារម្មណ៍របស់យើងផ្លាស់ប្ដូរពីការសោកសៅទៅកាន់ការដឹងគុណ ។ យើងមានអំណរគុណយ៉ាងខ្លាំងចំពោះអ្វីដែលយើងបានរៀនសូត្រពីព្យាការីដ៏អស្ចារ្យរបស់ព្រះរូបនេះ ។

នៅថ្ងៃនេះ ក្នុងការជួបជុំគ្នាដ៏ឧឡារិកនេះ យើងបានប្រតិបត្តិតាមឆន្ទៈនៃព្រះអម្ចាស់ ដែលទ្រង់មានបន្ទូលថា "ការណ៍នេះមិនបានអនុញ្ញាតដល់អ្នកណាមួយ ដើម្បីឱ្យចេញទៅផ្សាយដំណឹងល្អរបស់យើង ឬដើម្បីឱ្យស្ថាបនាសាសនាចក្ររបស់យើងឡើងឡើយ លើកលែងតែអ្នកនោះបានតែងតាំងឡើងដោយ...នរណាម្នាក់ដែលមានសិទ្ធិអំណាច ហើយ *ការតែងតាំងនោះត្រូវបានទទួលស្គាល់ចំពោះសាសនាចក្រ* ថាអ្នកនោះមានសិទ្ធិអំណាច ហើយបានតែងតាំងដោយត្រឹមត្រូវ ដោយពួកអ្នកដឹកនាំនៃសាសនាចក្រ" ។1 ក្រិត្យវិន័យនៃការលើកដៃគាំទ្រជាទូទៅនេះត្រូវបានគេធ្វើឡើង ហើយសាសនាចក្រនឹងឆ្ពោះទៅមុខនៅលើកិច្ចការដែលបានធ្វើអនុសាសន៍ឡើងរបស់ខ្លួន ។

សមាជិកទាំងឡាយទូទាំងពិភពលោកគាំទ្រប្រធាន ថូម៉ាស អេស ម៉នសុន និងទីប្រឹក្សាដ៏មានសមត្ថភាពរបស់លោក ។ យើង "មិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេគឺជាជនជាតិតែមួយនឹងពួកបរិសុទ្ធជាពួកដំណាក់ព្រះវិញ ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក" ។3

ព្រះអម្ចាស់បានបើកសម្ដែងនូវហេតុផលដែល "ទ្រង់បានប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវក ខ្លះជាគ្រូអធិប្បាយ" ។ ការណ៍នេះដើម្បជា "ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង : "ទាល់តែយើងរាល់គ្នាបានរួបរួមខាងសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ" ។4

ហេតុដូចនេះហើយ ការបំរើរបស់ពួកសាវក---គណៈប្រធានទីមួយ និងពួក 12 នាក់---គឺដើម្បីនាំមកនូវការរួបរួមខាងសេចក្ដីជំនឿនោះ និងដើម្បីប្រកាសចំណេះរបស់យើងស្ដីពីលោកចៅហ្វាយ ។ ការបំរើរបស់យើង គឺដើម្បីប្រសិទ្ធិពរ ដល់ជីវិតនៃជនទាំងឡាយណាដែលនឹងរៀន ហើយធ្វើតាម "ផ្លូវមួយដ៏ប្រសើរលើសលែងទៅទៀត"របស់ព្រះអម្ចាស់ ។5 ហើយយើងនឹងជួយមនុស្សដែលរៀបចំខ្លួនសំរាប់សក្ដានុពលនៃការសង្គ្រោះ និងការលើកដំកើងរបស់ពួកគេ ។

មាត្រានៃសេចក្ដីជំនឿខទីបីប្រកាសថា "តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះដោយសារការគោរពតាមក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ"។

ដើម្បីត្រូវសង្គ្រោះ---ឬដើម្បីទទួលបាននូវការសង្គ្រោះ--- មានន័យថាការសង្គ្រោះចេញពីសេចក្ដីស្លាប់ខាងរូបកាយ និងខាងវិញ្ញាណ។ ដោយសារការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ ហើយត្រូវបានសង្គ្រោះចេញពីសេចក្ដីស្លាប់ខាងរូបកាយ។ មនុស្សទាំងអស់ក៏អាចត្រូវបានសង្គ្រោះចេញពីសេចក្ដីស្លាប់ខាងវិញ្ញាណរបស់ខ្លួនម្នាក់ៗតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ តាមរយៈសេចក្ដីជំនឿរបស់ពួកគេចំពោះទ្រង់ តាមរយៈការរស់នៅដោយគោរពប្រតិបត្តិចំពោះក្រិត្យវិន័យ និងពិធីបរិសុទ្ធនៃដំណឹងល្អរបស់ទ្រង់ ព្រមទាំងតាមរយៈការបំរើទ្រង់។

ដើម្បីត្រូវបានលើកដំកើង---ឬដើម្បីទទួលបាននូវការលើកដំកើង--- សំដៅទៅលើសណ្ឋានខ្ពស់បំផុតនៃសុភមង្គល និងភាពរុងរឿងនៅក្នុងនគរសេឡេស្ទាល។ ពរជ័យទាំងនេះអាចកើតមានចំពោះយើង បន្ទាប់ពីយើងបោះបង់ចោលនូវភាពទន់ខ្សោយ និងជីវិតរមែងស្លាប់នេះ។ ពេលវេលាដើម្បីរៀបចំខ្លួនសំរាប់ការសង្គ្រោះ និងការលើកដំកើងនៅទីបញ្ចប់របស់យើង គឺជាពេលឥឡូវនេះ។6

ជាផ្នែកនៃការរៀបចំខ្លួននោះ ជាដំបូង បុគ្គលម្នាក់ត្រូវតែស្ដាប់ឮ ហើយយល់នូវដំណឹងល្អ។ ពីព្រោះតែហេតុផលនេះ ហើយដែលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទកំពុងតែត្រូវបាននាំយកទៅដល់ "គ្រប់អស់ទាំងសាសន៍ គ្រប់ទាំងពូជអំបូរ គ្រប់ភាសា ហើយទាំងគ្រប់គ្រួសារដែរ"។7

## ការទទួលខុសត្រូវផ្ទាល់ខ្លួន

ប៉ុន្មានឆ្នាំមុន ខ្ញុំបានជួបនឹងស្ដេចនៃកុលសម្ព័ន្ធនៅប្រទេសអាហ្វ្រិក។ នៅពេលដែលគាត់បានដឹងថា គាត់កំពុងតែត្រូវបានបង្រៀនដោយសាវកនៃព្រះអម្ចាស់ នោះគាត់ត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំង។ គាត់បានមានប្រសាសន៍ថាប្រជាជនរបស់គាត់ជាច្រើននឹងត្រូវបានជ្រមុជទឹក ប្រសិនបើគាត់នឹងផ្ដល់នូវការអនុញ្ញាតឱ្យពួកគេធ្វើបែបនេះ។ ខ្ញុំបានថ្លែងអំណរគុណដល់គាត់ចំពោះសណ្ដានចិត្តរបស់គាត់ ប៉ុន្តែបានពន្យល់ថា ព្រះអម្ចាស់ពុំធ្វើកិច្ចការតាមរបៀប នោះឡើយ។

ការអភិវឌ្ឍនៃសេចក្ដីជំនឿលើព្រះអម្ចាស់ គឺជាបញ្ហារបស់បុគ្គលម្នាក់ឯង។ ការប្រែចិត្តក៏ជាបញ្ហារបស់បុគ្គលផងដែរ។ មានតែជាបុគ្គលម្នាក់អាចត្រូវបានជ្រមុជទឹក និងទទួលព្រះវិញ្ញាណបរិសុទ្ធ។ យើងម្នាក់ៗត្រូវបានចាប់កំណើតមកតែម្នាក់ឯងដូចគ្នានេះដែរ យើងម្នាក់ៗត្រូវបាន "កើតម្ដងទៀត"8 តែម្នាក់ឯង។ សេចក្ដីសង្គ្រោះ គឺជាបញ្ហាបុគ្គល។

## ការទទួលខុសត្រូវជាគ្រួសារ

ការរីកចំរើនផ្ទាល់ខ្លួន ត្រូវបានថែទាំនៅក្នុងគ្រួសារ ដែលជា "ចំណុចសំខាន់ចំពោះផែនការនៃអង្គបង្កបង្កើតសំរាប់ជោគវាសនាដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់"។ 9 គេហដ្ឋានគឺជាទីកន្លែងដែលព្រះសព្វព្រះទ័យឱ្យយើងរៀននូវរបៀបផ្ដល់សេចក្ដីស្រឡាញ់ និងទទួលនូវការស្រឡាញ់ ព្រមទាំងការបំរើ។ ដែលមានស្វាមីម្នាក់ស្រឡាញ់ភរិយារបស់ខ្លួន ដែលមានភរិយាម្នាក់ស្រឡាញ់ស្វាមីរបស់ខ្លួន ឪពុកម្ដាយ និងកូនៗស្រឡាញ់គ្នាទៅវិញទៅមក។

នៅជុំវិញពិភពលោក គ្រួសារស្ថិតនៅក្រោមការវាយប្រហារកាន់តែខ្លាំងឡើង។ ប្រសិនបើក្រុមគ្រួសារបរាជ័យ នោះប្រព័ន្ធខាងនយោបាយ សេដ្ឋកិច្ច និងសង្គមរបស់យើងជាច្រើននឹងបរាជ័យផងដែរ។ ហើយប្រសិនបើក្រុមគ្រួសារបរាជ័យ នោះសក្តានុពលដ៏នៅអស់កល្បជានិច្ចប្រកបដោយភាពរុងរឿងរបស់ពួកគេ ពុំអាចដឹងទុកជាមុនឡើយ។

ព្រះវរបិតាសួគ៌របស់យើងសព្វព្រះទ័យឱ្យស្វាមី និងភរិយាទាំងឡាយស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក ហើយត្រូវគោរព និងប្រព្រឹត្តចំពោះកូនចៅរបស់ខ្លួនឱ្យដូចជាមរតកមកពីព្រះអម្ចាស់។ 10 នៅក្នុងក្រុមគ្រួសារបែបនោះយើងអាចសិក្សាព្រះគម្ពីរ និងអធិស្ឋានរួមគ្នា។ ហើយយើងធ្វើការផ្តោតយកចិត្តទុកដាក់របស់យើងទៅលើព្រះវិហារបរិសុទ្ធ។ នៅទីនោះយើងទទួលពរជ័យដ៏ខ្ពស់បំផុតដែលព្រះបានរៀបចំទុកសំរាប់កូនចៅដ៏ស្មោះត្រង់របស់ទ្រង់។

សូមថ្លែងអំណរគុណដល់ផែនការនៃសុភមង្គលដ៏មហិមារបស់ទ្រង់11 ក្រុមគ្រួសារអាចរស់នៅជានិន្តរ៍---ជាបុគ្គលដែលត្រូវបានលើកដំកើង។ ព្រះវរបិតាសួគ៌របស់យើងបានប្រកាសថា: "នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង---គឺដើម្បីនាំឱ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស"។ 12 គោលបំណងទាំងពីររបស់ទ្រង់ គឺអាចធ្វើទៅបានតាមរយៈដង្វាយធួននៃព្រះរាជបុត្រាស្ងួនភ្ងាររបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ ដង្វាយធួនរបស់ទ្រង់បានធ្វើឱ្យការរស់ឡើងវិញក្លាយជាការពិត និងជីវិតដ៏នៅអស់កល្បជានិច្ចអាចកើតមានឡើងសំរាប់ មនុស្សទាំងអស់ដែលមានជីវិតរស់នៅ។

ការរស់ឡើងវិញ ឬអមតភាពកើតមានចំពោះបុរស និងស្ត្រីគ្រប់រូបជាអំណោយទានដោយគ្មានលក្ខខណ្ឌ។

ជីវិតដ៏នៅអស់កល្បជានិច្ច ឬភាពរុងរឿងសេឡេស្ទាល ឬការលើកដំកើង គឺជាអំណោយទានដែលមានលក្ខខណ្ឌ។ លក្ខខណ្ឌនៃអំណោយទាននេះត្រូវបានបង្កើតឡើងដោយព្រះអម្ចាស់ដែលទ្រង់បានមានបន្ទូលថា "បើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះអ្នកនឹងបានជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ"។13 លក្ខខណ្ឌជោគជ័យទាំងនោះ រួមមានទាំងសេចក្តីជំនឿលើព្រះអម្ចាស់ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ការទទួលព្រះវិញ្ញាណបរិសុទ្ធ និងការកាន់ខ្ជាប់ដរាបដល់ចុងបំផុតដោយស្មោះត្រង់ចំពោះពិធីបរិសុទ្ធ និងសេចក្តីសញ្ញានៃព្រះវិហារបរិសុទ្ធ។

គ្មានបុរសណាម្នាក់នៅក្នុងសាសនាចក្រនេះ អាចទទួលបាននូវកិរិតដ៏ខ្ពស់បំផុតនៃភាពរុងរឿងសេឡេស្ទាលដោយគ្មានស្ត្រីដែលមានភាពសក្តិសមម្នាក់ដែលបានផ្សារភ្ជាប់នឹងគាត់នោះឡើយ។14 ពិធីការព្រះវិហារបរិសុទ្ធធ្វើឱ្យការលើកដំកើងនៅទីបញ្ចប់សំរាប់ពួកគេទាំងពីរកើតមានឡើង។

នៅក្នុងការហៅរបស់សាសនាចក្រ យើងអាចត្រូវបានគេដោះលែង។ ប៉ុន្តែយើងមិនអាចត្រូវបានគេដោះលែងក្នុងនាមជាឪពុកម្តាយនោះឡើយ។ ចាប់ពីជំនាន់ដំបូងបង្អស់នៃប្រវត្តិសាស្ត្រមនុស្សជាតិ ព្រះអម្ចាស់បានបញ្ជាឪពុកម្តាយឱ្យបង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួន។15 លោក ម៉ូសេ បានសរសេរថា : "ត្រូវប្រិតប្រៀន... ដល់កូនចៅឯងព្រមទាំងនិយាយដំណាលនៃ [ព្រះបន្ទូលរបស់ព្រះ] ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវក្នុងកាលដែលដេកហើយក្រោកឡើងផង"។16

នៅក្នុងជំនាន់របស់យើង ព្រះអម្ចាស់បានបន្ថែមថា "ឱ្យចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្ដីពិត"។17 សាសនាចក្រនឹងជួយ តែមិនដកយកឪពុកម្ដាយចេញពីការទទួលខុសត្រូវរបស់ពួកគេ ដើម្បីបង្រៀនកូនចៅរបស់ពួកគេឡើយ។

នៅក្នុងថ្ងៃនៃអំពើទុច្ចរិតដ៏ធំទូលាយ និងការញៀនរូបអាសគ្រាម ឪពុកម្ដាយមាននូវការទទួលខុសត្រូវពិសិដ្ឋមួយ ដើម្បីបង្រៀនកូនចៅរបស់ខ្លួននូវសារៈសំខាន់នៃព្រះនៅក្នុងជីវិតរបស់ពួកគេ។18 រឿងទុច្ចរិតទាំងនោះ ជាការបំផ្លិចបំផ្លាញដែលមានកំរិតខ្ពស់បំផុតដល់សក្ដានុពលដ៏ទេវភាព គឺគប្បីត្រូវបានជៀសវាងដោយកូនចៅនៃព្រះ។

យើងក៏ត្រូវបង្រៀនកូនចៅរបស់យើងផងដែរឱ្យគោរពឪពុកម្ដាយរបស់ខ្លួន។ ក្រិត្យវិន័យទីប្រាំថ្លែងថា "ចូរឱ្យគោរពប្រណិបត្តិដល់ឪពុកម្ដាយ : ដើម្បីឱ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់ប្រទានឱ្យ"។19

តើយើងអាចបង្រៀនកូនចៅរបស់យើងឱ្យល្អបំផុតយ៉ាងដូចម្ដេច? ព្រះអម្ចាស់ផ្ដល់ឱ្យយើងនូវការណែនាំដ៏ជាក់លាក់ថា : " គ្មានអំណាច ឬឥទ្ធិពលណាអាច ឬគប្បីបានរក្សាដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ"

"ដោយចិត្តល្អ និងដោយការចេះដឹងពេញទី ដែលនឹងពង្រីកព្រលឹងឱ្យធំទូលំទូលាយ ដោយឥតលាក់ពុត និងដោយឥតមានឧបាយកលឡើយ---ដោយស្ដីបន្ទោសសមពេលសមហេតុ ដោយការតឹងរឹង កាលណាបានបំផុសដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មក ដោយបង្ហាញនូវសេចក្ដីស្រឡាញ់ដ៏ច្រើនឡើងចំពោះអ្នកនោះដែលអ្នកបានស្ដីបន្ទោស ក្រែងអ្នកនោះរាប់អ្នកថាជាខ្មាំងសត្រូវរបស់គេ"។20

នៅពេលកូនណាមួយត្រូវការការកែតំរូវ អ្នកគួរតែសួរខ្លួនឯងថា "តើខ្ញុំអាចនិយាយ ឬធ្វើអ្វីខ្លះ ដែលនឹងជួយវាឱ្យជ្រើសរើសផ្លូវដ៏ប្រសើរមួយ?" ពេលដែលត្រូវធ្វើនូវការកែតំរូវដ៏ចាំបាច់ សូមធ្វើការណ៍នោះដោយស្ងៀមស្ងាត់ជាឯកជនដោយសេចក្ដីស្រឡាញ់ ហើយកុំធ្វើជាសាធារណៈ។ ប្រសិនបើការស្ដីបន្ទោសបានតំរូវឱ្យមាន រំពេចនោះចូរបង្ហាញការពង្រីកនូវសេចក្ដីស្រឡាញ់ ដើម្បីកុំឱ្យមានអារម្មណ៍នូវការអាក់អន់ចិត្តរវាងអ្នកទាំងពីរ។ ដើម្បីឱ្យមានការបញ្ចុះបញ្ចូល សេចក្ដីស្រឡាញ់របស់អ្នកត្រូវតែមានភាពស្មោះស្ម័គ្រ ហើយការបង្រៀនរបស់អ្នកផ្ដោតទៅលើគោលលទ្ធិដ៏ទេវភាព និងគោលការណ៍ដ៏ត្រឹមត្រូវ។

កុំព្យាយាមគ្រប់គ្រងកូនចៅរបស់អ្នក។ តែផ្ទុយទៅវិញ សូមស្ដាប់ពួកគេ ជួយពួកគេឱ្យរៀននូវដំណឹងល្អដែលបំផុតគំនិតដល់ពួកគេ និងដឹកនាំពួកគេឆ្ពោះទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច។ អ្នកគឺជាភ្នាក់ងាររបស់ព្រះនៅក្នុងការថែទាំកូនចៅដែលទ្រង់បានផ្ដល់នូវការទុកចិត្តចំពោះអ្នក។ ចូរឱ្យឥទ្ធិពលដ៏ទេវភាពរបស់ទ្រង់គង់នៅក្នុងដួងចិត្តរបស់អ្នកពេលដែលអ្នកបង្រៀន និងបញ្ចុះបញ្ចូល។

## បុព្វជន

ការពិភាក្សានានា ស្ដីពីការទទួលខុសត្រូវជាគ្រួសារដើម្បីរៀបចំខ្លួន សំរាប់ការលើកដំកើងនឹងមិនពេញលេញ ប្រសិនបើយើងបានរួមបញ្ចូលតែម្ដាយ ឪពុក និងកូនចៅប៉ុណ្ណោះ។ ចុះចំពោះលោកតាលោកយាយ និងបុព្វជនដទៃទៀតវិញ? ព្រះអម្ចាស់បានបើកសម្ដែងថា យើងមិនអាចប្រែក្លាយជាល្អឥតខ្ចោះដោយ គ្មានពួកគាត់បានឡើយ ហើយពួកគេក៏

មិនអាចធ្វើឱ្យបានល្អឥតខ្ចោះដោយគ្មានយើងបានដែរ ។21ពិធីការផ្សារភ្ជាប់ គឺចាំបាច់ណាស់ចំពោះការលើកដំកើង ។ ភរិយាម្នាក់ត្រូវតែផ្សារភ្ជាប់នឹងស្វាមីរបស់នាង កូនៗត្រូវតែផ្សារភ្ជាប់នឹងឪពុកម្ដាយរបស់ពួកគេ ហើយយើងទាំងអស់គ្នាត្រូវតែផ្សារភ្ជាប់នឹងបុព្វជនរបស់យើង ។ 22

ចុះចំពោះជនទាំងឡាយណាដែលពុំអាចរៀបអាពាហ៍ពិពាហ៍នៅក្នុងជីវិតនេះ ឬជនទាំងឡាយដែលពុំអាចផ្សារភ្ជាប់នឹងឪពុកម្ដាយរបស់ពួកគេនៅក្នុងជីវិតនេះវិញ? យើងដឹងថា ព្រះអម្ចាស់នឹងកាត់សាច់ក្ដីយើងម្នាក់ៗ ស្របតាមចំណង់នៃដួងចិត្តរបស់យើង ក៏ដូចជាកិច្ចការរបស់យើង23 ហើយថាពរជ័យនៃការលើកដំកើង នឹងត្រូវបានប្រទានឱ្យចំពោះជនទាំងអស់ណាដែលមានភាពសក្ដិសម ។ 24

យើងទាំងអស់គ្នា ក្នុងនាមជាកូនចៅនៃសេចក្ដីសញ្ញា គឺត្រូវបានអនុគ្រោះយ៉ាងខ្លាំង ។ នៅក្នុងដួងចិត្តរបស់យើងត្រូវបានបណ្ដុះនូវសេចក្ដីសន្យា ដែលបានធ្វើចំពោះលោកឪពុក អ័ប្រាហាំ អេសាយ និងយ៉ាកុប ។ ព្រះអម្ចាស់មានព្រះបន្ទូលថា: "អ្នករាល់គ្នាជាអ្នកគ្រងមរតកពេញច្បាប់ ស្របតាមសាច់ឈាម ហើយបានលាក់ទុកពីពិភពលោកដោយសារព្រះគ្រីស្ទនៅក្នុងព្រះ ។

"ហេតុដូច្នេះហើយ អ្នករាល់គ្នាមានពរហើយ បើសិនជាអ្នករាល់គ្នាបន្តនៅក្នុងសេចក្ដីល្អរបស់យើង គឺជាពន្លឺដល់ពួក សាសន៍ដទៃ និងតាមរយៈបព្វជិតភាពនេះ គឺជាអ្នកសង្គ្រោះដល់រាស្ត្ររបស់យើងគឺសាសន៍អ៊ីស្រាអែល" ។25

ឆាកជីវិតនេះ គឺជាពេលវេលាដើម្បីរៀបចំខ្លួនសំរាប់សេចក្ដីសង្គ្រោះ និងការលើកដំកើង ។ 26 នៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ សេចក្ដីសង្គ្រោះគឺជារឿងរបស់បុគ្គល ការលើកដំកើងគឺជារឿងរបស់គ្រួសារ ។

ក្នុងនាមជាកូនចៅនៃសេចក្ដីសញ្ញា យើងបានជួបជុំគ្នានៅក្នុងការប្រមូលផ្ដុំដ៏ឧឡារិកនៅព្រឹកនេះ ។ គោលបំណងត្រូវបានយកចិត្តទុកដាក់ទៅលើងារពិសិដ្ឋនៃពួកព្យាការី និងពួកសាវក ។ ប៉ុន្ដែការទទួលខុសត្រូវចុងក្រោយបង្អស់ដើម្បីរៀបចំខ្លួនសំរាប់សេចក្ដីសង្គ្រោះ និងការលើកដំកើងស្ថិតនៅលើបុគ្គលម្នាក់ៗ ការទទួលខុសត្រូវឆ្លើយតបចំពោះការជ្រើសរើសផ្ទាល់ខ្លួន ការប្រព្រឹត្តនៅក្នុងគ្រួសារផ្ទាល់របស់បុគ្គលម្នាក់ ដោយទទួលងារពិសិដ្ឋមួយផ្សេងទៀត ជាម្ដាយឪពុក កូនស្រី កូនប្រុស លោកយាយ ឬលោកតា ។

នៅក្នុងតួនាទីទទួលខុសត្រូវទាំងនោះ សូមឱ្យយើងឆ្ពោះទៅមុខដោយសេចក្ដីជំនឿ បានដឹកនាំដោយ ព្រះយេស៊ូវគ្រីស្ទ ដែលនេះគឺជាសាសនាចក្ររបស់ទ្រង់ ហើយតាមរយៈព្យាការីរបស់ទ្រង់ ជាអ្នកដែលទ្រង់មានព្រះបន្ទូល ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. គ. និង ស. 42:11 ការសង្កត់ន័យគឺជាការបន្ថែម ។

2. សូមមើល គ. និង ស. 26:2; 28:13 ។

3. អេភេសូរ 2:19--20 ។

4. អេភេសូរ 4:11--13 ។

5. កូរិនថូសទី 1 12:31 អេធើរ 12:11 ។

6. សូមមើល អាលម៉ា 34:32--33 ។

7. វិវរណៈ 14:6 ។

8. យ៉ូហាន 3:3, 7 ម៉ូសាយ 27:25 អាលម៉ា 5:49 7:14 ម៉ូសេ 6:59 ។

9. ក្រុមគ្រួសារ ៖ការប្រកាសដល់ពិភពលោក *Liahona* ខែ តុលា ឆ្នាំ 2004, 49 ។

10. សូមមើលទំនុកដំកើង 127:3 ។

11. សូមមើលអាលម៉ា 42:8 ។

12. ម៉ូសេ 1:39 ។

13. គ. និង ស. 14:7 សូមមើលផងដែរ នីហ្វៃទី 3 15:9 ។ ព្រះគម្ពីរមរមនបានពន្យល់ថែមទៀតនូវលក្ខខណ្ឌចម្បងជាតិនៃអំណោយទានដ៏មហិមានេះ ។ វាបានចែងថា ៖ "អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននូវនៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លា នៃសេចក្ដីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ *បើសិនជា* អ្នករាល់គ្នាខិតខំជឿនទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះនោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលដូច្នោះថា ៖ អ្នករាល់គ្នានឹងមានជីវិត ដ៏នៅអស់កល្បជានិច្ច" (នីហ្វៃទី 2 31:20 ការសង្កត់ន័យគឺជាការបន្ថែម) ។

14. សូមមើល គ. និង ស. 131:1--3 ។

15. សូមមើល ម៉ូសេ 6:57--58 ។ ផងដែរសូមកត់ចំណាំនូវការបង្រៀនរបស់ស្ដេចបេនយ៉ាមីនដែលថា ៖ "អ្នករាល់គ្នានឹងពុំទ្រាំឱ្យកូនចៅរបស់អ្នកអត់ឃ្លាន ឬគ្មានសំលៀកបំពាក់បិទបាំងកាយឡើយ ហើយអ្នករាល់គ្នាក៏ពុំឱ្យកូនចៅអ្នករំលងក្រិត្យវិន័យទាំងឡាយនៃព្រះ ហើយឈ្លោះប្រកែកគ្នាទៅវិញទៅមក ហើយបំរើអារក្សដែលជាចៅហ្វាយនៃអំពើបាប... ។ ប៉ុន្ដែអ្នករាល់គ្នានឹងបង្រៀនកូនចៅអ្នកឱ្យដើរតាមផ្លូវទាំងឡាយ ដែលពិត ហើយម៉ឺងម៉ាត់ អ្នករាល់គ្នានឹងបង្រៀនកូនចៅអ្នកឱ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយឱ្យបំរើគ្នាទៅវិញទៅមក" (ម៉ូសាយ 4:14--15) ។

16. ចោទិយកថា 6:7 ។

17. គ. និង ស. 93:40 ។ ព្រះអម្ចាស់បានមានបន្ទូលផងដែរថា ៖ "បង្រៀនកូនចៅ [របស់អ្នក] ឱ្យអធិស្ឋាន និងឱ្យដើរដោយទៀងត្រង់ នៅចំពោះព្រះអម្ចាស់" (គ. និង ស. 68:28) ។

18. ដូចដែលប៉ុលបានបង្រៀនទៅធីម៉ូថេថា ៖ "ចូរឱ្យអ្នកនៅជាប់ក្នុងសេចក្ដីដែលអ្នកបានរៀន ហើយជឿប្រាកដវិញ ដោយដឹងថាអ្នកបានរៀនសេចក្ដីនោះពីអ្នកណា... តាំងពីក្មេងតូចមកអ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មានដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង" (ធីម៉ូថេទី 2 3:14--15) ។

19. និក្ខមនំ 20:12 ។ សូមចងចាំថាសុភាសិតពីសាច់ញាតិបានសរសេរថា ៖ "ចូរបង្ហាត់កូនក្មេងឱ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្តនោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់" (សុភាសិត 22:6) ។

20. គ. និង ស. 121:41--43 ។

21. សូមមើល គ. និង ស. 128:15 ។

22. សូមមើល គ. និង ស. 128:18 ។

23. សូមមើល គ. និង ស. 137:9 ។

24. សូមមើល គ. និង ស. 130:20--21 សូមមើល ផងដែរ Rudger Clawson, នៅក្នុង *Conference Report* ខែតុលា ឆ្នាំ 1917, 29: Joseph F. Smith, នៅក្នុង *Deseret News* ថ្ងៃទី 1 ខែ ឧសភា ឆ្នាំ 1878 ទំព័រ 2 Richard G. Scott, "The Joy of Living the Great Plan of Happiness," *Ensign* ខែ វិច្ឆិកា
ឆ្នាំ 1996 ទំព័រ 75 ។

25. គ. និង ស. 86:9, 11 ។

26. សូមមើលអាលម៉ា 12:24 ។